# ធ្វើរឿងត្រឹមត្រូវនៅពេលត្រឹមត្រូវ ដោយមិនពន្យារពេល

*ដោយអែលឌើរ យ៉ូសេ អិល អាលុនសូ*
*នៃពួកចិតសិប*

នៅក្នុងសម័យរបស់យើងមនុស្សជាច្រើនកំពុងរស់នៅក្នុងភាពទុក្ខព្រួយ និងការច្របូកច្របល់ក្រៃលែង ។ ពួកគេពុំស្វែងរកចម្លើយសម្រាប់សំនួរទាំងឡាយរបស់ពួកគេទេ ហើយពុំអាចរកសេចក្ដីត្រូវការទាំងឡាយរបស់គេឃើញឡើយ ។ មនុស្សមួយចំនួនបានបាត់បង់ការចេះដឹងពីសុភមង្គល និងសេចក្ដីអំណរ ។ ពួកព្យាការីបានប្រកាសថាសុភមង្គលដ៏ពិតប្រាកដគឺបានមកពីការធ្វើតាមគំរូ និងការបង្រៀនទាំងឡាយរបស់ព្រះគ្រីស្ទ ។ ទ្រង់ជាអង្គសង្គ្រោះរបស់យើង ទ្រង់ជាគ្រូរបស់យើង ហើយទ្រង់ជាគំរូដ៏ឥតខ្ចោះ ។ ជីវិតទ្រង់គឺជាជីវិតនៃការបម្រើ ។

កាលណាយើងបម្រើដល់អ្នកជិតខាងយើងគឺយើងបម្រើដល់អ្នកទាំងឡាយដែលមានសេចក្ដីត្រូវការ ។ ខណៈនោះយើងក៏អាចរកឃើញនូវដំណោះស្រាយសម្រាប់ការលំបាកផ្ទាល់របស់យើងផ្ទាល់ ។ កាលណាយើងធ្វើតាមគំរូរបស់ព្រះអង្គសង្គ្រោះ នោះយើងបង្ហាញនូវសេចក្ដីស្រឡាញ់ដល់ព្រះវរបិតាសួគ៌យើង និងព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទ ហើយយើងកាន់តែក្លាយដូចជាទ្រង់ ។

ស្ដេចបេនយ៉ាមីនបានថ្លែងអំពីតម្លៃនៃការបម្រើ ដោយមានព្រះបន្ទូលថា កាលណាយើង « នៅការបម្រើដល់មនុស្សទូទៅ នោះ [ យើង ] រាល់គ្នាគ្រាន់តែនៅក្នុងការបម្រើដល់ព្រះរបស់ [ យើង ] តែប៉ុណ្ណោះ » ។ [1] មនុស្សគ្រប់រូបមានឱកាសដើម្បីផ្ដល់ការបម្រើ និងបង្ហាញសេចក្ដីស្រឡាញ់ ។

ប្រធានថូម៉ាស អេស ម៉នសុន បានសុំឲ្យយើងទៅ « ជួយសង្គ្រោះ » និងបម្រើអ្នកដទៃ ។ លោកបានមានប្រសាសន៍ថា « យើងនឹងរកឃើញថាអ្នកទាំងឡាយដែលយើងបម្រើ ទទួលបាននូវអារម្មណ៍នៃឥទ្ធិពលរបស់លោកថៅហ្វាយតាមរយៈការបម្រើរបស់យើង ដោយពុំអាចពន្យល់ពីការផ្លាស់ប្ដូរនៅក្នុងជីវិតរបស់ពួកគេបាន ។ ដោយមានបំណងបម្រើដោយស្មោះត្រង់ ដើរដោយបន្ទាបខ្លួន និងរស់នៅកាន់តែដូចព្រះអង្គសង្គ្រោះ ។ ដោយបានទទួលការយល់ដឹងខាងវិញ្ញាណ និងទិដ្ឋភាពនៃការសន្យាចំពោះភាពអស់កល្បជានិច្ច ពួកគេនិយាយនូវរឿងដូចដែលបុរសខ្វាក់ដែលព្រះយេស៊ូវបានព្យាបាលឲ្យជាថា ‹ ខ្ញុំដឹងតែប៉ុណ្ណេះថា ពីដើមខ្ញុំខ្វាក់តែឥឡូវនេះខ្ញុំមើលឃើញ › ។[2]

ជារៀងរាល់ថ្ងៃយើងមានឱកាសដើម្បីជួយ និងបម្រើគឺធ្វើរឿងត្រឹមត្រូវ នៅពេលត្រឹមត្រូវ ដោយមិនពន្យារពេល ។ ចូរគិតពីមនុស្សជាច្រើនដែលពិបាករកការងារ ឬមានជម្ងឺរេកោ ព្រមទាំងគិតថាពួកគេបាត់បង់អ្វីៗទាំងអស់ ។ តើអាចធ្វើអ្វីខ្លះដើម្បីជួយ ? ចូរស្រម៉ៃគិតថាមានអ្នកជិតខាងម្នាក់ បានខូចឡាននៅកណ្ដាលភ្លៀង ទូរស័ព្ទមកសុំអ្នកឲ្យជួយ ។ តើអ្វីគឺជារឿងត្រឹមត្រូវដើម្បីជួយគាត់ ? តើពេលណាជាពេលត្រឹមត្រូវដើម្បីធ្វើវា ?

ខ្ញុំនឹកចាំពីពេលមួយកាលយើងបានចេញទៅផ្សារក្នុងទីក្រុង ម៉ិកស៊ីកូជាក្រុមគ្រួសារ ដើម្បីទិញសម្លៀកបំពាក់សម្រាប់កូនទាំងពីររបស់យើង ។ ពួកគេនៅក្មេងណាស់ ។ កូនប្រុសបងរបស់យើងទើបតែមានអាយុពីរឆ្នាំ និងកូនប្រុសប្អូនអាយុមួយឆ្នាំ ។ មានមនុស្សពេញផ្លូវ ។ ខណៈពេលយើងកំពុងទិញឥវ៉ាន់ ដឹកដៃកូនរបស់យើង យើងបានឈប់មួយភ្លែតដើម្បីមើលវត្ថុផ្សេងៗ ហើយដោយពុំបានគិត យើងបានបាត់កូនប្រុសបងរបស់យើង! យើងពុំបានដឹងពីមូលហេតុដែលបានបាត់នោះទេ ប៉ុន្តែគាត់មិនបាននៅជាមួយយើងឡើយ ។ យើងបានរត់រកគាត់ដោយគ្មានពន្យារមួយវិនាទីណាឡើយ ។ យើងបានរក និងហៅគាត់ ស្ថិតក្នុងសភាពពោរពេញដោយការបារម្ភ ដោយគិតថាយើងប្រហែលជាបាត់គាត់ជារៀងរហូត ។ ក្នុងចិត្តយើង យើងទូលអង្វរដល់ព្រះវរបិតាសួគ៌សូមជួយយើងរកគាត់ឲ្យឃើញ ។

មួយសន្ទុះក្រោយមកយើងបានឃើញគាត់ ។ គាត់នៅទីនោះ មើលតុក្កតាតាមបង្អួចហាងមួយដោយមិនដឹងខ្លួន ។ ភរិយាខ្ញុំ និងខ្ញុំបានឱប និងថើបគាត់ ហើយយើងបានធ្វើការតាំងចិត្តថាមើលកូនៗរបស់យើងដោយប្រុងប្រយ័ត្នមិនឲ្យបាត់ម្នាក់ណាម្ដងទៀតឡើយ ។ យើងបានរៀនថាដើម្បីទៅជួយសង្គ្រោះកូនប្រុសរបស់យើង យើងមិនចាំបាច់មានការប្រជុំដាក់ផែនការទេ ។ យើងបានអនុវត្តដោយសាមញ្ញ ដោយចេញទៅរកកូនម្នាក់ដែលបានបាត់ ។ យើងក៏បានរៀនផងដែរថាកូនប្រុសយើងមិនបានដឹងថាគាត់វង្វេងនោះទេ ។

បងប្អូនប្រុសស្រី ដោយមូលហេតុមួយចំនួន មានមនុស្សជាច្រើនត្រូវបានវង្វេងចេញពីក្រសែភ្នែករបស់យើង ហើយពុំបានដឹងថាពួកគេវង្វេងឡើយ ។ បើយើងពន្យារពេល នោះយើងអាចបាត់គេជារៀងរហូត ។

ត្បិតមានមនុស្សជាច្រើនត្រូវការជំនួយពីយើង វាពុំចាំបាច់បង្កើតកម្មវិធីថ្មី ឬធ្វើសកម្មភាពដែលស្មុគស្មាញ ឬថ្លៃនោះទេ ។ វាត្រូវការតែការប្ដេជ្ញាចិត្តរបស់យើងដើម្បីបម្រើដើម្បីធ្វើរឿងត្រឹមត្រូវនៅពេលត្រឹមត្រូវ ដោយមិនពន្យារពេល ។ កាលដែលព្រះអង្គសង្គ្រោះយាងទៅជួបមនុស្សក្នុងព្រះគម្ពីរមរមន ទ្រង់បានផ្ដល់ឲ្យយើងនូវគំរូមួយដ៏អស្ចារ្យអំពីការកុំរង់ចាំដើម្បីបម្រើដល់អ្នកទាំងឡាយដែលបានបាត់បង់ការចេះដឹងពីសុភមង្គល និងសេចក្ដី

អំណរ ។ ឆ្លងកាត់ការបង្រៀន ទ្រង់បានទតឃើញថាពួកគេគ្មានលទ្ធភាពយល់ពីព្រះបន្ទូលរបស់ទ្រង់នោះទេ ។ ទ្រង់បានឲ្យពួកគេត្រឡប់ទៅផ្ទះវិញ ហើយពិចារណាពីរឿងទាំងឡាយដែលទ្រង់បានមានព្រះបន្ទូលទៅពួកគេ ។ ទ្រង់បានប្រាប់ពួកគេឲ្យអធិស្ឋានដល់ព្រះវរបិតា និងរៀបចំខ្លួនមកម្ដងទៀតនៅថ្ងៃស្អែក នៅពេលដែលទ្រង់យាងមកបង្រៀនពួកគេម្ដងទៀត ។[3]

កាលដែលទ្រង់បានបញ្ចប់ទ្រង់បានទតមើលពួកគេ ហើយបានឃើញថាពួកគេកំពុងតែយំ ព្រោះពួកគេមានបំណងឲ្យទ្រង់នៅជាមួយនឹងពួកគេ ៖ « ហើយទ្រង់មានព្រះបន្ទូលទៅពួកគេថា ៖ មើលចុះចិត្តយើងពោរពេញទៅដោយសេចក្ដីអាណិតមេត្តាដល់អ្នករាល់គ្នា ។

« តើនៅក្នុងចំណោមអ្នករាល់គ្នាមានអ្នកណាឈឺទេ? ចូរនាំអ្នកទាំងនោះមកទីនេះចុះ ។ តើមាននរណាខ្វិន ឬខ្វាក់ ឬគ ឬបាក់ដៃបាក់ជើង ឬឃ្លង់ ឬស្វិតស្រពន់ ឬថ្លង់ ឬក៏ត្រូវរងទុក្ខដោយហេតុណាផ្សេងទៀត? ចូរនាំពួកគេមកទីនេះចុះ ហើយយើងនឹងប្រោសឲ្យពួកគេបានជា ត្បិតយើងមានចិត្តអាណិតអាសូរដល់ពួកគេ ចិត្តយើងពោរពេញទៅដោយសេចក្ដីមេត្តាករុណា ។[4]

ហើយពួកគេបាននាំអ្នកឈឺរបស់ពួកគេមកឯទ្រង់ ហើយទ្រង់បានព្យាបាលពួកគេ ។ ហ្វូងមនុស្សបានក្រាបចំពោះព្រះបាទាទ្រង់ ហើយបានថ្វាយបង្គំទ្រង់ និងបានថើបព្រះបាទាទ្រង់ « ដរាបដល់ព្រះបាទាទ្រង់សើមជោកជាំដោយទឹកភ្នែករបស់ពួកគេ » ។ ហើយទ្រង់បានបញ្ជាឲ្យយកកូនតូចៗរបស់ពួកគេមក ហើយទ្រង់បានប្រទានពរដល់ពួកគេម្នាក់ម្ដងៗ ។[5] នោះគឺជាគំរូដែលព្រះអង្គសង្គ្រោះបានប្រទានដល់យើងទាំងអស់គ្នា ។ សេចក្ដីស្រឡាញ់របស់ទ្រង់គឺសម្រាប់មនុស្សទូទៅ ប៉ុន្តែទ្រង់មិនដែលភ្លេចនរណាម្នាក់ឡើយ ។

ខ្ញុំដឹងថាព្រះវរបិតាសួគ៌យើងពោរពេញដោយក្ដីស្រឡាញ់ ព្រះតម្រិះ និងទប់ព្រះទ័យ ។ ព្រះរាជបុត្រារបស់ទ្រង់ ព្រះយេស៊ូវគ្រីស្ទក៏ស្រឡាញ់យើងដែរ ។ ទ្រង់ផ្ដល់ជំនួយដល់យើងតាមរយៈពួកព្យាការីរបស់ទ្រង់ ។ ខ្ញុំបានរៀនថាវាមានសុវត្ថិភាពពេលធ្វើតាមពួកព្យាការី ។ « ការជួយសង្គ្រោះនៅតែមាន » ប្រធានម៉នសុន បានមានប្រសាសន៍ថា ៖ « ព្រះអម្ចាស់រំពឹងឲ្យយើងគិត ។ ទ្រង់រំពឹងឲ្យយើងអនុវត្ត ។ ទ្រង់រំពឹងឲ្យយើងធ្វើកិច្ចការ ។ ទ្រង់រំពឹងលើទីបន្ទាល់របស់យើង ។ ទ្រង់រំពឹងឲ្យយើងលះបង់ » ។[6]

យើងមាននូវការទទួលខុសត្រូវ និងឱកាសដ៏មហិមា ។ មានមនុស្សជាច្រើនត្រូវការភ្លក់បទពិសោធន៍ផ្អែមល្ហែមនៃសុភមង្គល និងសេចក្ដីអំណរតាមរយៈសកម្មភាពក្នុងសាសនាចក្រម្ដងហើយម្ដងទៀត ។ សុភមង្គលនោះមកពីការទទួលពិធីបរិសុទ្ធ ការធ្វើសេចក្ដីសញ្ញានានា និងការគោរពតាមសេចក្ដីសញ្ញាទាំងនោះ ។ ព្រះអម្ចាស់ត្រូវការយើងឲ្យជួយដល់ពួកគេ ។ ចូរយើងធ្វើរឿងត្រឹមត្រូវនៅពេលត្រឹមត្រូវដោយមិនពន្យារ ។

ខ្ញុំសុំថ្លែងទីបន្ទាល់ថា ព្រះមានព្រះជន្មរស់ ហើយទ្រង់ជាព្រះវរបិតារបស់យើង ។ ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ ហើយលះបង់ព្រះជន្មរបស់ទ្រង់ដើម្បីឲ្យយើងអាចត្រឡប់ទៅឯទីវត្តមានរបស់ព្រះវរបិតាសួគ៌យើងវិញ ។ ខ្ញុំដឹងថាទ្រង់ជាអង្គសង្គ្រោះរបស់យើង។ ខ្ញុំដឹងថាសេចក្ដីមេត្តាករុណាដ៏គ្មានទីបញ្ចប់របស់ទ្រង់នៅតែបន្តបើកសម្ដែង ។ ខ្ញុំសូមធ្វើទីបន្ទាល់ថា ប្រធានថូម៉ាស អេស ម៉នសុន ជាព្យាការីរបស់ទ្រង់ ហើយថានេះគឺជាព្រះវិហារពិតតែមួយគត់នៅលើផ្ទៃផែនដី ។ ខ្ញុំដឹងថាព្យាការីយ៉ូសែប ស្ម៊ីធជាព្យាការីនៃការស្ដារឡើងវិញ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថាព្រះគម្ពីរមរមនគឺព្រះបន្ទូលរបស់ព្រះ ។ វាផ្ដល់ដល់យើងនូវការណែនាំ និងលំនាំដើម្បីធ្វើតាមដើម្បីឲ្យកាន់តែក្លាយដូចជាព្រះ និងព្រះរាជបុត្រារបស់ទ្រង់ ។ ខ្ញុំសូមប្រកាសនៅក្នុងព្រះនាមព្រះអម្ចាស់យេស៊ូវគ្រីស្ទរបស់យើង អាម៉ែន ។

កំណត់ចំណាំ

1. ម៉ូសាយ 2:17 ។
2. ថូម៉ាស អេស ម៉នសុន « To the Rescue » *Liahona* ខែ កក្កដា ឆ្នាំ 2001 ទំព័រ 57, 58, *Ensign* ខែ ឧសភា ឆ្នាំ 2001 ទំព័រ 48, 49 ។
3. សូមមើល នីហ្វៃទី3 17: 1–3 ។
4. នីហ្វៃទី3 17: 6-7 សូមមើលខទី5 ផងដែរ ។
5. សូមមើលនីហ្វៃទី3 17:9–12, 21 ។
6. ថូម៉ាស អេស ម៉នសុន *Liahona* ខែ កក្កដា ឆ្នាំ 2001 ទំព័រ 58 *Ensign* ខែ ឧសភា ឆ្នាំ 2001 ទំព័រ 49 ។